Ministry of Foreign Affairs and
International Cooperation
Kingdom of Cambodia
OFFICE OF THE SPOKESPERSON

# បច្ចុប្បន្នភាពស្តីពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ
# ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥

I. **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត៖** កម្ពុជាដោះស្រាយបញ្ហាព្រំដែនជាមួយភាគីថៃ ដោយសន្តិវិធី ដោយផ្អែកលើកិច្ចព្រមព្រៀងទ្វេភាគី អនុសញ្ញា សន្ធិសញ្ញា ដែលមានស្រាប់ និងច្បាប់អន្តរជាតិ

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា** បាន អនុញ្ញាតឱ្យឯក**ឧត្តម ឧត្តមសេនីយ៍ទោ Dato Paduka Seri Haji Muhammad Haszaimi Bin Bol Hassan អគ្គមេបញ្ជាការកងទ័ពភូមិន្ទព្រុយណេ (RBAF)** ចូលជួប សម្តែងការគួរសម និងពិភាក្សាការងារ។ ក្នុងជំនួបនោះ បញ្ហាពាក់ពន្ធ័នឹងស្ថានភាពនៅព្រំ ដែនរវាងកម្ពុជានិងថៃ ត្រូវបានលើកយកទៅពិភាក្សាផងដែរ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានឆ្លៀតឱកាសថ្លែងអំណរគុណដល់ព្រុយណេដែលបានគាំទ្រ និងបានចូលរួមក្នុងក្រុម អ្នកសង្កេតការណ៍អន្តរកាល (IOT) ។ **សម្តេចធិបតី** ក៏បាន បានគូសបញ្ជាក់ពីជំហររបស់ កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយភាគីថៃ ដោយសន្តិវិធី ផ្អែកលើកិច្ចព្រមព្រៀង ទ្វេភាគី អនុសញ្ញា និងសន្ធិសញ្ញា ដែលមានស្រាប់ និងច្បាប់អន្តរជាតិ។

ជាការឆ្លើយតប **ឯកឧត្តម ឧត្តមសេនីយ៍ទោ Dato Paduka Seri Haji Muhammad Haszaimi Bin Bol Hassan** បានគូសបញ្ជាក់ពីការបន្តគាំទ្ររបស់ព្រុយណេលើយន្តការក្រុម អ្នកសង្កេតការណ៍អន្តរកាល (IOT) និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការដោះ ស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃដោយសន្តិវិធី ដើម្បីរក្សាបាននូវសន្តិភាពយូរអង្វែងរវាង ប្រទេសជិតខាងទាំងពីរ ក៏ដូចជា សន្តិភាពនៅក្នុងតំបន់ទាំងមូល។

II. **សម្តេចធិបតីនាយករដ្ឋមន្ត្រី៖ រាជរដ្ឋាភិបាលបន្តខិតខំប្រឹងប្រែងដើម្បីការដោះលែង និងការ ត្រឡប់មកវិញដោយសុវត្ថិភាពរបស់ទាហានកម្ពុជា ១៨ នាក់ ដែលត្រូវបានឃុំខ្លួន ដោយ កងទ័ពថៃ**

រាជរដ្ឋាភិបាលបាន និងកំពុងបន្តព្យាយាមយ៉ាងសកម្ម តាមរយៈយន្តការទាំងអស់ ដើម្បី ស្វែងរកដំណោះស្រាយក្នុងការការពារអាយុជីវិត និងសុវត្ថិភាពរបស់ពលរដ្ឋកម្ពុជា និង ព្យាយាមអស់ពីសមត្ថភាពសម្រាប់ការដោះលែង និងការត្រឡប់មកមាតុភូមិវិញដោយ

សុវត្ថិភាពរបស់ទាហានកម្ពុជា ១៨ នាក់ដែលត្រូវបានឃុំខ្លួន ដោយទាហានថៃ ក្រោយកិច្ចព្រមព្រៀងឈប់បាញ់ចូលជាធរមាន។

នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០២៥ សម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត បានជួបសំណេះសំណាលជាមួយគ្រួសារទាហានកម្ពុជា ១៨ នាក់ ដែលត្រូវបានកងកម្លាំងប្រដាប់អាវុធថៃឃុំខ្លួនក្រោយកិច្ចព្រមព្រៀងបញ្ឈប់បាញ់ បានចូលជាធរមាននៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២៥។ ក្នុងកំឡុងពេលជួបសំណេះសំណាលនោះ សម្តេចធិបតី បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការខិតខំធានាអោយបាននូវសុខភាព និងសុវត្ថិភាពរបស់ទាហានទាំង ១៨ នាក់ និងធានាអោយមានការវិលត្រឡប់មកមាតុភូមិវិញក្នុងពេលឆាប់ៗ។

## III. ករណីឧបទ្ទវហេតុនៅភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ៖

**នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០២៥ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានចេញសេចក្តីថ្លែងការណ៍** ដោយបាន "ស្នើដោយទាមទារដល់រដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធថៃឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពដែលរំលោភលើអធិបតេយ្យភាពកម្ពុជា និងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា ហើយត្រូវប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិនិងតំបន់។"

## IV. កម្ពុជាត្រូវការសុខសន្តិភាព។ សន្តិភាពដែលមិនត្រឹមសម្រាប់ពលរដ្ឋកម្ពុជានិងថៃប៉ុណ្ណោះទេ តែសម្រាប់សហគមន៍អាស៊ានទាំងមូល

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភាកម្ពុជា បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិត តាន់ស៊ី ដាតូ ហ្សូហារី ប៊ីន អាប់ឌុល** (Tan Sri Dato (Dr.) Johari Bin Abdul) ប្រធានរដ្ឋសភានៃប្រទេសម៉ាឡេស៊ី និងជាប្រធានអាយប៉ាលើកទី៤៦ ក្នុងពេលដែល **សម្តេច** អញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៦ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

**សម្តេចមហារដ្ឋសភាធិការធិបតី** បានថ្លែងអំណរគុណដល់ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិម៉ាឡេស៊ី ដែលខិតខំសម្របសម្រួលនៅក្នុងការបង្កើតឱ្យមានបទឈប់បាញ់និងចូលសង្កេតការណ៍យ៉ាងយកចិត្តទុកដាក់លើការអនុវត្តបទឈប់បាញ់ និងបន្តតាមដានសភាពការណ៍ជាប់ជាប្រចាំ។

**សម្តេចមហារដ្ឋសភាធិការធិបតី** បានគូសរំលេចថា "*កម្ពុជាត្រូវការសុខសន្តិភាព។ សន្តិភាពដែលមិនត្រឹមសម្រាប់ពលរដ្ឋកម្ពុជានិងថៃប៉ុណ្ណោះទេ តែសម្រាប់សហគមន៍អាស៊ានទាំងមូល។*" **សម្តេច** ក៏បានរំលេចថា "*ក្នុងនាមសមាជិកអាស៊ាន យើងត្រូវការពារសុខសន្តិភាពក្នុងតំបន់ មិន*

*គួរបណ្តោយឱ្យបញ្ហាជាអវិភាពណាមួយ រីកាលដាលកាន់តែធំសម្រាប់គ្រួសារអាស៊ាននោះឡើយ។"*

V. **ក្រសួងការបរទេសកម្ពុជា៖ កម្ពុជាជំទាស់យ៉ាងខ្លាំងចំពោះចេតនារបស់ថៃ ក្នុងការអនុវត្តច្បាប់ក្នុងស្រុករបស់ខ្លួន ទៅលើពលរដ្ឋកម្ពុជា** ក្នុងសេចក្តីថ្លែងការណ៍ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២៥ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានគូសបញ្ជាក់នូវការតវ៉ា និងការជំទាស់យ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះចេតនារបស់ប្រទេសថៃ ក្នុងការអនុវត្តច្បាប់ក្នុងស្រុករបស់ខ្លួន លើប្រជាពលរដ្ឋកម្ពុជា នៅភូមិជោគជ័យ និងភូមិព្រៃចាន់ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

កម្ពុជាសូមអំពាវនាវឱ្យថៃបញ្ឈប់សកម្មភាពនានា ដែលធ្វើអោយប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីបន្ធូរបន្ថយភាពតានតឹង ដូចដែលបានតាំងចិត្តរួមគ្នា ក្រោមកិច្ចព្រមព្រៀង បទឈប់បាញ់ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០២៥ និងកំណត់ហេតុរបស់គណៈកម្មាធិការព្រំដែនទូទៅទូទៅ ( GBC) កាលពីថ្ងៃទី ៧ ខែសីហា និងថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០២៥។

រាជរដ្ឋាភិបាលកម្ពុជា បញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួន និងឥតងាករេក្នុងការស្វែងរកដំណោះស្រាយប្រកបដោយមិត្តភាព ចំពោះជម្លោះព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ តាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ខណៈរក្សាការប្តេជ្ញាចិត្តប្រកាន់ខ្ជាប់គោលជំហរជាគោលការណ៍ថា ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយការប្រើកម្លាំងនោះឡើយ។ រាជរដ្ឋាភិបាលកម្ពុជាក៏សូមរក្សាសិទ្ធរបស់ខ្លួន ក្រោមច្បាប់អន្តរជាតិ និងមិនចាត់តុកការប្រើប្រាស់ច្បាប់ក្នុងស្រុករបស់ថៃ ថាមានប្រសិទ្ធភាពផ្លូវច្បាប់ ឬប៉ះពាល់ដល់ដំណើរការវាស់វែង និងខណ្ឌសីមារួមនោះឡើយ។

VI. ត្រឹមថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ ជា**ថ្ងៃទី៥៣** ហើយ ដែលវីរកងទ័ពកម្ពុជា ចំនួន **១៨រូប** ត្រូវបានចាប់ឃុំខ្លួនដោយយោធាថៃ ក្រោយបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ កម្ពុជាអំពាវនាវឱ្យភាគីថៃ ដោះលែងកងទ័ពកម្ពុជាទាំង ១៨រូប ប្រកបដោយសុខសុវត្ថិភាព គ្មានលក្ខខណ្ឌ ស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ។

**Ministry of Foreign Affairs and**
**International Cooperation**
**Kingdom of Cambodia**
**OFFICE OF THE SPOKESPERSON**

---

## Updates on the situation of the Cambodia-Thailand border
## 20 September 2025

### I. Samdech Thipadei HUN Manet, Prime Minister of the Kingdom of Cambodia: Commitment to resolving the border issue with Thailand through peaceful means, based on bilateral agreements and international law.

On September 19, 2025, Samdech Thipadei HUN Manet, Prime Minister of the Kingdom of Cambodia, received a courtesy call from His Excellency Major General Dato Paduka Seri Haji Muhammad Haszaimi Bin Bol Hassan, Commander-in-Chief of the Royal Brunei Armed Forces (RBAF). During the meeting, the issue of the Cambodia–Thailand border situation was raised.

Samdech Thipadei Prime Minister expressed his appreciation to Brunei for its support and participation in the Interim Observers Team (IOT), as well as for its support of the ceasefire agreement and efforts toward a peaceful resolution of the border dispute between Cambodia and Thailand. He reaffirmed Cambodia's firm position to resolve the border issue with Thailand peacefully, on the basis of existing bilateral agreements, conventions, treaties, and in accordance with international law.

In response, H.E. Dato Paduka Seri Haji Muhammad Haszaimi Bin Bol Hassan reaffirmed Brunei's support for the IOT mechanism and underscored the importance of resolving the Cambodia–Thailand border issue in order to safeguard lasting peace between the two neighboring countries, as well as peace and stability in the region as a whole.

## II. Samdech Thipadei HUN Manet, Prime Minister of the Kingdom of Cambodia: Ongoing efforts for the release and safe return of the 18 detained Cambodian soldiers

The Government has been, and continues to be, actively engaged through all available mechanisms to seek solutions aimed at safeguarding the lives and safety of Cambodian citizens, and to make every effort for the prompt release and safe return of the 18 detained soldiers.

On September 19, 2025, Samdech Thipadei HUN Manet, Prime Minister of the Kingdom of Cambodia, together with the First Lady, met with the families of the 18 Cambodian military personnel currently detained by the Thai armed forces since the ceasefire agreement entered into force at midnight on 28 July 2025. During the social gathering – Samdech Thipadei reaffirmed the Royal Government of Cambodia's unwavering commitment to ensuring the health and well-being of the 18 soldiers and to securing their immediate return.

## III. On the incident at Prey Chan village, O Bei Choan commune, O Chrov district, Banteay Meanchey province:

On September 18, 2025, the Cambodian Human Rights Committee issued a statement demanded that "the Royal Government and Armed Forces of Thailand to immediately cease all acts violating Cambodia's sovereignty and the rights and freedoms of the Cambodian people, and to strictly comply with their obligations under international and regional law."

## IV. Cambodia wants peace, not only for the people of Cambodia and Thailand, but for the entire ASEAN community

On September 20, 2025, **Samdech Maha Rathsapheathika Thipadei Khuon Sudary, President of the National Assembly** had a meeting **with H.E. Tan Sri Dato (Dr.) Johari Bin Abdul, Speaker of the House of Representatives of Malaysia and President of AIPA-46**, in Kuala Lumpur. **During the discussion, Samdech Khuon Sudary** expressed gratitude to the Malaysian legislative and

executive bodies for their efforts to facilitate the establishment of a ceasefire and their attentive observation on the implementation of the ceasefire, and continue to monitor the ceasefire and the situation regularly. She also stressed that "*Cambodia wants peace, not only for the people of Cambodia and Thailand, but for the entire ASEAN community.*" She emphasized that "*As ASEAN members, we must protect regional peace and security and not allow any hostile issues to spread further into the ASEAN family.*"

V. **Ministry of Foreign Affairs and International Cooperation of Cambodia sent strong protest and objection against Thailand's intention to apply its domestic law on Cambodian citizens—**

In its Statement released 20 September 2025, the Ministry of Foreign Affairs and International Cooperation of Cambodia reiterated the protest and strong objection of the Royal Government of Cambodia to Thailand's intention to apply its domestic law on Cambodian national in Chork Chey and Prey Chan villages, O' Bei Choan commune, O' Chrov district, Banteay Meanchey province.

Cambodia calls on Thailand to cease all activities that undermine joint efforts to de-escalate the situation as mutually committed under the Ceasefire Agreement of 28 July 2025, and the Agreed Minutes of the General Border Committee (GBC) dated 7 August and 10 September 2025.

The Statement added that – "The Royal Government of Cambodia reaffirms its consistent and unwavering commitment to seeking an amicable resolution to all boundary disputes with all its neighbors through peaceful means in accordance with international law, while remaining resolute in upholding its principled position that borders must not be changed by force. The Royal Government of Cambodia also reserves all its rights under international law and does not consider Thailand's assertions of domestic law to have any legal effect or prejudice to the joint survey and demarcation process."

**VI.** As of September 20, 2025, it has been **53** days since **18** Cambodian soldiers were captured under captivity of the Thai military. Cambodia urgently calls on the Thai side to release them as soon as possible, unconditional, and in accordance with international humanitarian law.